**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

លេខ: ២០៩៦/.........ប្រក.ប.ស្ក /០៣/២៥

# ប្រកាស
## ស្តីពី
## ការទទួលខុសត្រូវរបស់អ្នកផលិត អ្នកនាំចូល ឬអ្នកផ្គត់ផ្គង់ផ្តាច់មុខលើ បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ក្រោយប្រើប្រាស់រួច ឬលែងប្រើប្រាស់បានក្លាយជាសំណល់

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើក្រមបរិស្ថាននិងធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក
- បានឃើញប្រកាសលេខ ៧៨២ សហវ.ប្រក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ២០២២
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន



អគារមរតកតេជោ ឡូតិ៍លេខ503 ផ្លូវកៅស៊ូរមហាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ទូរស័ព្ទ: 023 235 004 / 023 235 006

## សម្រេច

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងកំណត់ការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកផលិត អ្នកនាំចូល ឬអ្នកផ្គត់ផ្គង់ផ្ដាច់មុខលើបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ក្រោយពេលប្រើប្រាស់រួច ឬលែងប្រើបានក្លាយជាសំណល់ សំដៅពង្រឹងការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកប្រកបដោយសុវត្ថិភាពបរិស្ថាន។

**ប្រការ២.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើរូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកផលិត អ្នកនាំចូល ឬអ្នកផ្គត់ផ្គង់ផ្ដាច់មុខលើប្រភេទបរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលមានបញ្ញត្តិក្នុងតារាងឧបសម្ព័ន្ធ១នៃប្រកាសនេះ។

ប្រភេទបរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលមានបញ្ញត្តិក្នុងតារាងឧបសម្ព័ន្ធ១នៃប្រកាសនេះ អាចកែប្រែបានតាមរយៈប្រកាសរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

**ប្រការ៣.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកផលិត អ្នកនាំចូល ឬអ្នកផ្គត់ផ្គង់ផ្ដាច់មុខលើបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ត្រូវទទួលខុសត្រូវក្នុងការប្រមូលបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ក្រោយពេលប្រើប្រាស់រួច ឬលែងប្រើបានក្លាយជាសំណល់។

រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកផលិតអ្នកនាំចូលឬផ្គត់ផ្គង់ផ្ដាច់មុខលើបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ត្រូវរៀបចំ និងអនុវត្តប្រព័ន្ធប្រមូលដោយខ្លួនឯងដោយមានការអនុញ្ញាតពីក្រសួងបរិស្ថាន ឬសហការជាមួយក្រុមហ៊ុនផ្តល់សេវាប្រមូល ដឹកជញ្ជូន និងទុកដាក់សំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលមានលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន។

ការរៀបចំការប្រមូល ដឹកជញ្ជូន និងទុកដាក់សំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក មានដូចខាងក្រោម៖

- រៀបចំយន្តការប្រមូល ដឹកជញ្ជូន និងទុកដាក់សំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក
- រៀបចំទីតាំងប្រមូល ដោយធ្វើការបែងចែក និងដាក់ស្លាកសញ្ញាសម្គាល់ប្រភេទសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក
- រៀបចំទីតាំងទុកដាក់ចុងក្រោយសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលប្រមូលបាន ឬត្រូវនាំត្រឡប់ទៅប្រទេសដើមវិញ។

**ប្រការ៤.-**

រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកផលិត អ្នកនាំចូល ឬអ្នកផ្គត់ផ្គង់ផ្ដាច់មុខលើបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ត្រូវទទួលខុសត្រូវគ្រប់គ្រង និងប្រព្រឹត្តិកម្មសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលប្រមូលបាន។

រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកផលិត អ្នកនាំចូល ឬអ្នកផ្គត់ផ្គង់ផ្ដាច់មុខលើបរិក្ខារអគ្គិសនី និងអេឡិចត្រូនិក អាចប្រើប្រាស់សេវាប្រព្រឹត្តិកម្មសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលមានលិខិតអនុញ្ញាតពីក្រសួងបរិស្ថាន ឬធ្វើការនាំចេញសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកទៅប្រទេសដើមវិញ។

ការនាំចេញសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកត្រូវអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៥..**

រូបវន្តបុគ្គល ឬនីតិបុគ្គលជាអ្នកផលិត អ្នកនាំចូល ឬអ្នកផ្គត់ផ្គង់ផ្តាច់មុខលើបរិក្ខារអគ្គិសនី និងអេឡិចត្រូនិកត្រូវរាយការណ៍ពីបរិមាណ និងប្រភេទបរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលបាននាំចូល និងបរិមាណ និងប្រភេទសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលប្រមូលបានមកក្រសួងបរិស្ថានរៀងរាល់ ៦(ប្រាំមួយ)ខែ ដោយប្រើប្រាស់ទម្រង់របាយការណ៍ដែលបានកំណត់ក្នុងឧបសម្ព័ន្ធ២នៃប្រកាសនេះ។

**ប្រការ៦..**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧..**

អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃអង្គារ ៤រោច ខែផល្គុន ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមីនា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**អ៊ាង សុផល្លែត**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ១

## ប្រភេទបរិក្ខារអគ្គិសនី និងអេឡិចត្រូនិកក្រោមបញ្ញត្តិ

| លេខទីតាំង | ប្រភេទបរិក្ខារ | លេខកូដទំនិញ | បរិយាយមុខទំនិញ |
|---|---|---|---|
| 8415 | ម៉ាស៊ីនកំណត់សីតុណ្ហភាពខ្យល់ (ម៉ាស៊ីនត្រជាក់) ដែលមានកង្ហារប្រើម៉ូទ័រ និងឧបករណ៍សម្រាប់ផ្លាស់ប្តូរសីតុណ្ហភាព និងសំណើម ដោយរាប់បញ្ចូលម៉ាស៊ីនទាំងឡាយណាដែលមិនអាចកំណត់សំណើមដាច់ដោយឡែក | 8415.10 | - នៃប្រភេទដំឡើងជាប់បង្អួច ជញ្ជាំង ពិដាន ឬកម្រាល ដែលមានតួតែមួយ ឬ "ប្រព័ន្ធដាច់ពីគ្នា" |
| | | 8415.10.20 | - - ដែលមានសមត្ថភាពធ្វើឱ្យត្រជាក់ មិនលើស ២១ គីឡូវ៉ាត់ ១០. |
| | | 8415.10.30 | - - ដែលមានសមត្ថភាពធ្វើឱ្យត្រជាក់ លើស ២១ គីឡូវ៉ាត់ តែមិនលើស ១០. ៣៨.២៦ គីឡូវ៉ាត់ |
| | | 8415.10.90 | - - ផ្សេងទៀត |
| 8418 | ទូទឹកកក ទូបង្កក និងឧបករណ៍ធ្វើឱ្យកកផ្សេងទៀត ដំណើរការដោយអគ្គិសនី ឬផ្សេងទៀត ស្នប់កំដៅក្រៅពីម៉ាស៊ីនកំណត់សីតុណ្ហភាពខ្យល់នៃទីតាំង ៨៤.១៥ | 8418.10 | - ទូទឹកកកមានភ្ជាប់ទូបង្កក ដែលមានបំពាក់ទ្វារ និង ឬថត/ខាងក្រៅដាច់ដោយឡែក៖ |
| | | | - - ដែលមានបំពាក់ទ្វារខាងក្រៅ ដាច់ដោយឡែក តែប៉ុណ្ណោះ៖ |
| | | 8418.10.31 | - - - ប្រភេទប្រើប្រាស់ក្នុងផ្ទះ ដែលមានចំណុះ មិនលើស ២៣០ លីត្រ |
| | | 8418.10.32 | - - - ប្រភេទប្រើប្រាស់ក្នុងផ្ទះ ដែលមានចំណុះ លើស ២៣០ លីត្រ |
| | | 8418.21 | - - ប្រភេទប្រើកុំប្រេស័រ៖ |
| | | 8418.21.10 | - - - ដែលមានចំណុះ មិនលើស ២៣០ លីត្រ |
| | | 8418.21.90 | - - - ផ្សេងទៀត |
| | | 8418.29.00 | - - ផ្សេងទៀត |

| | | | |
|---|---|---|---|
| | | 8418.30 | - ទូបង្កកជាប្រភេទទូទ្រវែង ចំណុះមិនលើស ៨០០ លីត្រ៖ |
| | | 8418.30.10 | - - ដែលមានចំណុះមិនលើស ២០០ លីត្រ |
| | | 8418.30.90 | - - ផ្សេងទៀត |
| | | 8418.40 | - ទូបង្កកជាប្រភេទបញ្ឈរ ចំណុះមិនលើស ៩០០ លីត្រ៖ |
| | | 8418.40.10 | - - ដែលមានចំណុះមិនលើស ២០០ លីត្រ |
| | | 8418.40.90 | - - ផ្សេងទៀត |
| 8443 | ម៉ាស៊ីនបោះពុម្ពដោយប្រើសម្រាប់ការបោះពុម្ពដោយបន្ទះ ស៊ីឡាំងពុម្ព និងសមាសភាគសម្រាប់បោះពុម្ពផ្សេងទៀតនៃទីតាំង ៨៤.៤២ ម៉ាស៊ីនបោះពុម្ពផ្សេងទៀត ម៉ាស៊ីនថតចម្លង ម៉ាស៊ីនទូរសារ ទោះបីមាន ឬគ្មានមុខងាររួមគ្នាក្នុងម៉ាស៊ីនតែមួយ បំណែកភាគ និងគ្រឿងបន្លាប់បន្សំនៃម៉ាស៊ីនទាំងនេះ | 8443.39 | - - ផ្សេងទៀត៖ |
| | | 8443.39.40 | - - - ម៉ាស៊ីនបោះពុម្ព ដោយប្រើទឹកថ្នាំ |
| | | 8443.99 | - - ផ្សេងទៀត៖ |
| | | 8443.99.20 | - - - កាទ្រីជម៉ាស៊ីនបោះពុម្ពប្រើទឹកថ្នាំ |
| | | 8443.99.90 | - - - ផ្សេងទៀត |
| 8450 | ម៉ាស៊ីនបោកគក់ខោអាវប្រើក្នុងផ្ទះ ឬសម្រាប់សេវាកម្មបោកគក់ រួមទាំងម៉ាស៊ីនបោកផង និងសំងួតផង | | - ម៉ាស៊ីនបោកគក់ ដែលមានចំណុះខោអាវស្ងួតមិនលើស ១០ គក្រ.៖ |
| | | 8450.11 | - - ម៉ាស៊ីនស្វ័យប្រវត្តិ៖ |
| | | 8450.11.10 | - - - ដែលមានចំណុះខោអាវស្ងួតមិនលើស ៦ គក្រ. |
| | | 8450.11.90 | - - - ផ្សេងទៀត |
| | | 8450.12 | - - ម៉ាស៊ីនផ្សេងទៀត ដែលមានភ្ជាប់ឧបករណ៍សំងួតខាងក្នុងប្រើចលនាចាកផ្ចិត៖ |
| | | 8450.12.10 | - - - ដែលមានចំណុះខោអាវស្ងួតមិនលើស ៦ គក្រ. |
| | | 8450.12.90 | - - - ផ្សេងទៀត |

| | | | |
|---|---|---|---|
| | | 8450.19 | - - ផ្សេងទៀត៖ |
| | | | - - - ដំណើរការដោយអគ្គិសនី |
| | | 8450.19.11 | - - - - ដែលមានចំណុះខោអាវស្ងួតមិនលើស ៦ គក្រ. |
| | | 8450.19.19 | - - - - ផ្សេងទៀត |
| | | | - - - ផ្សេងទៀត៖ |
| | | 8450.19.99 | - - - - ដែលមានចំណុះខោអាវស្ងួតមិនលើស ៦ គក្រ. |
| | | 8450.20.00 | - ម៉ាស៊ីន ដែលមានចំណុះខោអាវស្ងួតលើស ១០ គក្រ.៖ |
| 8471 | ម៉ាស៊ីនប្រតិបត្តិការទិន្នន័យដោយស្វ័យប្រវត្តិ និងគ្រឿងរបស់វា ម៉ាស៊ីនអានម៉ាញ៉េទិក ឬអុបទិក ម៉ាស៊ីនចម្លងទិន្នន័យនៅលើឧបករណ៍រក្សាទិន្នន័យក្នុងទម្រង់ជាលេខកូដ និងម៉ាស៊ីនសម្រាប់ប្រតិបត្តិការទិន្នន័យទាំងនោះ ដែលមិនមានចែង ឬបញ្ចូលក្នុងទីតាំងណាមួយ | 8471.30 | - ម៉ាស៊ីនប្រតិបត្តិការទិន្នន័យដោយស្វ័យប្រវត្តិដែលងាយចល័ត មានទម្ងន់មិនលើស ១០ គក្រ. យ៉ាងតិចមានអង្គប្រតិបត្តិទិន្នន័យកណ្តាលមួយ (CPU) ក្តារចុចមួយ និងអេក្រង់មួយ៖ |
| | | 8471.30.20 | - - កុំព្យូទ័រយួរដៃ រួមទាំងកុំព្យូទ័រប្រភេទ notebooks និងប្រភេទ subnotebooks |
| | | 8471.30.90 | - - ផ្សេងទៀត |
| | | | - ម៉ាស៊ីនប្រតិបត្តិការទិន្នន័យដោយស្វ័យប្រវត្តិផ្សេងទៀត៖ |
| | | 8471.41 | - - ដែលយ៉ាងហោចមានក្នុងឯកតាតែមួយនូវអង្គប្រតិបត្តិការទិន្នន័យកណ្តាលមួយ (CPU) និងឧបករណ៍បញ្ចូលទិន្នន័យមួយ និងឧបករណ៍បញ្ចេញទិន្នន័យមួយ ទោះជាបាន ឬមិនបានផ្គុំចូលគ្នា៖ |
| | | 8471.41.10 | - - - កុំព្យូទ័រផ្ទាល់ខ្លួន ក្រៅពីកុំព្យូទ័រយួរដៃនៃទីតាំងរង ៨៤៧១៣០. |
| | | 8471.41.90 | - - - ផ្សេងទៀត |
| | | 8471.49 | - - ផ្សេងទៀត ដែលបង្ហាញនៅក្នុងទម្រង់ជាប្រព័ន្ធ៖ |
| | | 8471.49.10 | - - - កុំព្យូទ័រផ្ទាល់ខ្លួន ក្រៅពីកុំព្យូទ័រងាយចល័តនៃទីតាំងរង ៨៤៧១៣០. |

| | | | |
|---|---|---|---|
| | | 8471.49.9 | - - - ផ្សេងទៀត |
| 8506 | ថ្មពិល និងអាគុយ ប្រភេទមិនអាចសាកបាន | | ថ្មពិល និងអាគុយ ប្រភេទមិនអាចសាកបាន |
| | | 8506.10 | - ពីម៉ង់កាណែសឌីអុកស៊ីត៖ |
| | | | - - មានទំហំ សម ៣០០ មិនលើស (មានខាងក្រៅ)[៣] |
| | | 8506.10.11 | - - - ស័ង្កសីកាបូន |
| | | 8506.10.12 | - - - អាល់កាឡាំង |
| | | 8506.10.19 | - - - ផ្សេងទៀត |
| | | | - - ផ្សេងទៀត៖ |
| | | 8506.10.91 | - - - ស័ង្កសីកាបូន |
| | | 8506.10.99 | - - - ផ្សេងទៀត |
| | | 8506.30.00 | - ពីបារតអុកស៊ីត |
| | | 8506.40.00 | - ពីប្រាក់អុកស៊ីត |
| | | 8506.50.00 | - ពីលីចូម |
| | | 8506.60 | - ពីស័ង្កសីធ្វើអុកស៊ីតកម្មជាមួយខ្យល់៖ |
| | | 8506.60.10 | - - មានទំហំ សម ៣០០ មិនលើស (មានខាងក្រៅ)[៣] |
| | | 8506.60.90 | - - ផ្សេងទៀត |
| | | 8506.80 | - ថ្មពិល និងអាគុយផ្សេងទៀត មិនអាចសាកបាន៖ |
| | | 8506.80.30 | - - មានទំហំ សម ៣០០ មិនលើស (មានខាងក្រៅ)[៣] |
| | | 8506.80.90 | - - ផ្សេងទៀត |
| 8507 | | 8507.10 | - អាស៊ីតសំណ ប្រភេទប្រើប្រាស់សម្រាប់បញ្ឆេះម៉ាស៊ីនពីស្តុង៖ |

| | | | |
|---|---|---|---|
| | ឧបករណ៍ផ្ទុកថាមពលអគ្គិសនី (សាកបាន) ដោយរាប់បញ្ចូលទាំងសន្ទះខណ្ឌរបស់វា ទោះជាមាន ឬមិនមានរាងចតុកោណកែង (រាប់បញ្ចូលទាំងរាងជាការ៉េ) | | - - ផ្សេងទៀត៖ |
| | | | - - - មានតង់ស្យុងធម្មតា ៦ វ៉ុល ឬ១២ វ៉ុល ដែលអាចបញ្ចេញថាមពលមិនលើស ២០០ អំពែម៉ោង៖ |
| | | 8507.10.92 | - - - - ដែលមានកម្ពស់ ១៣ មិនលើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) សម |
| | | 8507.10.95 | - - - - ដែលមានកម្ពស់ សម ១៣ លើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) សម ២៣ ប៉ុន្តែមិនលើស |
| | | 8507.10.96 | - - - - ដែលមានកម្ពស់ សម ២៣ លើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) |
| | | | - - - ផ្សេងទៀត៖ |
| | | 8507.10.97 | - - - - ដែលមានកម្ពស់ ១៣ មិនលើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) សម |
| | | 8507.10.98 | - - - - ដែលមានកម្ពស់ សម ១៣ លើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) សម ២៣ ប៉ុន្តែមិនលើស |
| | | 8507.10.99 | - - - - ដែលមានកម្ពស់ សម ២៣ លើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) |
| | | 8507.20 | - ឧបករណ៍ផ្ទុកថាមពលអគ្គិសនី សំណផ្សេងទៀត៖ អាស៊ីត (សាកបាន) |
| | | | - - ផ្សេងទៀត៖ |
| | | | - - - មានតង់ស្យុងធម្មតា ៦ វ៉ុល ឬ១២ វ៉ុល ដែលអាចបញ្ចេញថាមពលមិនលើស ២០០ អំពែម៉ោង៖ |

| | | | |
|---|---|---|---|
| | | 8507.20.94 | ---- ដែលមានកម្ពស់ ១៣ មិនលើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) សម |
| | | 8507.20.95 | ---- ដែលមានកម្ពស់ សម ១៣ លើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) ប៉ុន្តែមិនលើស ២៣ សម |
| | | 8507.20.96 | ---- ដែលមានកម្ពស់ (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរសម ២៣ លើស) |
| | | | --- ផ្សេងទៀត៖ |
| | | 8507.20.97 | ---- ដែលមានកម្ពស់ ១៣ មិនលើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) សម |
| | | 8507.20.98 | ---- ដែលមានកម្ពស់ សម ១៣ លើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) សម ២៣ ប៉ុន្តែមិនលើស |
| | | 8507.20.99 | ---- ដែលមានកម្ពស់ សម ២៣ លើស (មិនរាប់បញ្ចូលក្បាលចាប់ និងដៃយួរ) |
| | | 8507.60 | - អ៊ីយ៉ុងលីចូម៖ |
| | | | -- បន្ទះថ្មសាកបាន៖ |
| | | 8507.60.31 | --- ប្រភេទប្រើប្រាស់ជាមួយកុំព្យូទ័រយួរដៃ រាប់បញ្ចូលកុំព្យូទ័រប្រភេទ notebooks និងប្រភេទ subnotebooks |
| | | 8507.60.32 | --- ជាប្រភេទប្រើប្រាស់សម្រាប់យន្តហោះ |
| | | 8507.60.33 | --- ប្រភេទប្រើប្រាស់សម្រាប់យានយន្តក្នុងជំពូកទី ៨៧ |
| | | 8507.60.39 | --- ផ្សេងទៀត |
| | | 8507.60.90 | -- ផ្សេងទៀត |

| | | | |
|---|---|---|---|
| | | 8507.80 | - ឧបករណ៍ផ្ទុកថាមពលអគ្គិសនី ផ្សេងទៀត៖ (សាកបាន) |
| | | 8507.80.20 | - - ប្រភេទប្រើជាមួយកុំព្យូទ័រយួរដៃ រាប់បញ្ចូលទាំងកុំព្យូទ័រទំហំប៉ុនសៀវភៅសរសេរ និងកុំព្យូទ័រទំហំប៉ុនកូនសៀវភៅ |
| | | | - - ផ្សេងទៀត៖ |
| | | 8507.80.91 | - - - ដែកនីកែល |
| | | 8507.80.99 | - - - ផ្សេងទៀត |
| 8517 | ទូរស័ព្ទជាឈុត រាប់បញ្ចូលទាំងទូរស័ព្ទបណ្ដាញសែលុយឡា ឬបណ្ដាញគ្មានខ្សែផ្សេងទៀត បរិធានផ្សេងទៀតសម្រាប់បញ្ជូន ឬទទួលសំឡេង រូបភាព ឬទិន្នន័យផ្សេងទៀត រាប់បញ្ចូលទាំងបរិធានសម្រាប់ទំនាក់ទំនងបណ្ដាញមានខ្សែ ឬគ្មានខ្សែ (ដូចជាបណ្ដាញតភ្ជាប់តំបន់មូលដ្ឋាន និងបណ្ដាញតភ្ជាប់តំបន់ឆ្ងាយ) ក្រៅពីបរិធានបញ្ជូន ឬទទួលផ្សេងទៀតនៃទីតាំង ៨៤.៤៣ ៨៥.២៥ ៨៥.២៧ ឬ៨៥.២៨ | 8517.13.00 | - - ទូរស័ព្ទវៃឆ្លាត |
| | | 8517.18.00 | - - ផ្សេងទៀត |
| 8528 | ម៉ូនីទ័រ និងឧបករណ៍បញ្ចាំង មិនភ្ជាប់ដោយបរិធានទទួលទូរទស្សន៍; បរិធានទទួលសម្រាប់ទូរទស្សន៍ ទោះមាន ឬគ្មានភ្ជាប់ឧបករណ៍ | | - បរិធានទទួលសម្រាប់ទូរទស្សន៍ ទោះជាមាន ឬគ្មានភ្ជាប់ជាមួយនឹងបរិធានទទួលការផ្សាយវិទ្យុ ឬបរិធានថត ឬផលិតឡើងវិញនូវសំឡេង ឬវីដេអូ៖ |
| | | 8528.71 | - - មិនផលិតឡើងសម្រាប់ភ្ជាប់អេក្រង់បញ្ចាំងវីដេអូ៖ |
| | | | - - - ប្រអប់ Set Top ដែលមានមុខងារទំនាក់ទំនង៖ |

| | | | |
|---|---|---|---|
| | ទទួលការផ្សាយវិទ្យុ ឬបរិធានថត ផលិតឡើងវិញនូវសំឡេង និងវីដេអូក៏ដោយ | 8528.71.11 | - - - - ដំណើរការដោយអគ្គិសនី |
| | | 8528.71.19 | - - - - ផ្សេងទៀត |
| | | | - - - ផ្សេងទៀត៖ |
| | | 8528.71.91 | - - - - ដំណើរការដោយអគ្គិសនី |
| | | 8528.71.99 | - - - - ផ្សេងទៀត |
| | | 8528.72 | - - ផ្សេងទៀត, មានពណ៌៖ |
| | | 8528.72.10 | - - - ដំណើរការដោយអាគុយ |
| | | | - - - ផ្សេងទៀត៖ |
| | | 8528.72.91 | - - - - ប្រភេទបំពង់កែវកាំរស្មីកាតូដ |
| | | 8528.72.92 | - - - - ប្រភេទ អិលស៊ីឌី (LCD), អិលអ៊ីឌី (LED) និងប្រភេទអេក្រង់សំប៉ែតផ្សេងទៀត |
| 8541 | ឧបករណ៍សិមីកុងឌុចទ័រ ( ឧ. យ៉ូត, ត្រង់ស៊ីស្ទ័រ ត្រង់ឌុស័រដែលមានមូលដ្ឋានពីសិមីកុងឌុចទ័រ ) ឧបករណ៍សិមីកុងឌុចទ័រដែលបំប្លែងពន្លឺទៅជាថាមពលអគ្គិសនី រាប់បញ្ចូលទាំងបន្ទះសូឡា ទោះបាន ឬមិនបានផ្គុំជាម៉ូឌុល ឬដំឡើងជាផ្ទាំង LED ទោះបាន ឬមិនបានផ្គុំជាមួយ LED ផ្សេងទៀត គ្រីស្តាល់ដែលមានបន្ទុកអគ្គិសនីដំឡើងរួច | | - ឧបករណ៍សិមីកុងឌុចទ័រដែលបំប្លែងពន្លឺទៅជាថាមពលអគ្គិសនី, រាប់បញ្ចូលទាំងបន្ទះសូឡា ទោះបាន ឬមិនបានផ្គុំជាម៉ូឌុល ឬដំឡើងជាផ្ទាំង: LED៖ |
| | | 8541.41.00 | - - LED |
| | | 8541.42.00 | - - បន្ទះសូឡា មិនបានផ្គុំជាម៉ូឌុល ឬដំឡើងជាផ្ទាំង |
| | | 8541.43.00 | - - បន្ទះសូឡា បានផ្គុំជាម៉ូឌុល ឬដំឡើងជាផ្ទាំង |
| 9405 | | 9405.41 | - ឧបករណ៍បម្លែងពន្លឺជាថាមពលអគ្គិសនីសម្រាប់ប្រើតែជាមួយប្រភពពន្លឺ LED៖ |

| | | | |
|---|---|---|---|
| | ចង្កៀង និងជើងអំពូល រាប់បញ្ចូលទាំងភ្លើងបញ្ចាំងស្វែងរក និងភ្លើងបញ្ចាំងតាមគោលដៅ និងភាគបំណែករបស់វា ដែលមិនមានចែង ឬរាប់បញ្ចូលនៅទីតាំងផ្សេងទៀត ផ្លាកសញ្ញាមានភ្លើងបំភ្លឺ ផ្លាកយីហោមានភ្លើងបំភ្លឺ និងវត្ថុប្រហាក់ប្រហែល ដែលមានប្រភពពន្លឺនៅនឹងមួយកន្លែង និងភាគបំណែករបស់វា មិនមានចែង ឬរាប់បញ្ចូលនៅទីតាំងផ្សេងទៀត | 9405.41.40 | - - - ប្រភេទផ្សេងទៀតប្រើសម្រាប់បំភ្លឺទីធ្លា ឬផ្លូវសាធារណៈ៖ ចង្កៀងប្រើនៅក្រៅអគារផ្សេងទៀត |
| | | 9405.41.90 | - - - ផ្សេងទៀត |
| | | 9405.42 | - - ផ្សេងទៀត សម្រាប់ប្រើតែជាមួយប្រភពពន្លឺ LED៖ |
| | | 9405.42.50 | - - - ប្រភេទផ្សេងទៀតប្រើសម្រាប់បំភ្លឺទីធ្លា ឬផ្លូវសាធារណៈ៖ |
| | | 9405.42.90 | - - - ផ្សេងទៀត |

*សម្គាល់៖ ទីតាំង និងលេខកូដទំនិញក្នុងតារាងខាងលើ សំដៅដល់ទីតាំង និងលេខកូដទំនិញដែលមានចែងក្នុងតារាងពន្ធគយកម្ពុជា*

**ឧបសម្ព័ន្ធ២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**

**អគ្គនាយកដ្ឋានគាំពារបរិស្ថាន**

នាយកដ្ឋានគ្រប់គ្រងសារធាតុគ្រោះថ្នាក់

## របាយការណ៍ស្តីពីការប្រមូលសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក

ខែ................. ដល់ខែ.......................

### ១. ព័ត៌មានទូទៅរបស់ក្រុមហ៊ុន

- ឈ្មោះក្រុមហ៊ុន៖.......................................................................................................
- អាសយដ្ឋានក្រុមហ៊ុន៖ផ្ទះលេខ...............ផ្លូវលេខ...............ក្រុមទី.................ភូមិ............ ឃុំ/សង្កាត់...........................ស្រុក/ខណ្ឌ............................ខេត្ត/រាជធានី .......................
- ប្រភេទអាជីវកម្ម៖....................................... ចាប់ផ្តើមដំណើរការនៅឆ្នាំ៖ ..........................
- ឈ្មោះអ្នកទំនាក់ទំនង៖...................................ភេទ៖.................សញ្ជាតិ៖.........................
- តួនាទីក្នុងក្រុមហ៊ុន៖............................អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ៖ ..........................
- ទូរស័ព្ទទំនាក់ទំនង៖.............................សារអេឡិចត្រូនិក៖ ..........................................

### ២. ព័ត៌មានបរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលបាននាំចូល

| លេខកូដ | ប្រភេទបរិក្ខារ | ចំនួន (គ្រឿង) | ទម្ងន់ (គីឡូក្រាម) |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

### ៣. ព័ត៌មានសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក

| ល.រ | ប្រភេទសំណល់ | ចំនួន (គ្រឿង) | ទម្ងន់ (គីឡូក្រាម) |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

*សម្គាល់៖ សូមភ្ជាប់រូបភាពនៃសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិកដែលបានប្រមូល។*

### ៤. ការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក

| ប្រភេទសំណល់ | សេវាប្រមូល | ទីតាំងប្រមូល | កាលបរិច្ឆេទប្រមូល |
|---|---|---|---|
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |
| | | | |

### ៥. ការទុកដាក់ចុងក្រោយ៖

- ☐ នាំចេញ៖ (ប្រទេសគោលដៅ)..........................................................................................
- ☐ កែច្នៃ៖ ឈ្មោះរោងចក្រកែច្នៃ ..........................................................................................

ថ្ងៃ...............................ខែ..............ឆ្នាំ........................ព.ស. ២៥៦....

ធ្វើនៅ............................. ថ្ងៃទី..................ខែ..............ឆ្នាំ២០.....

ហត្ថលេខា និងឈ្មោះអ្នករាយការណ៍